នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Oct-2014, 13:19
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

# ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្ដឹងសាទុក្ខសំណុំរឿង០០២/០១ និង សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវុឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**
សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
ពេជ អង្គ
Marie GUIRAUD

ជនជាប់ចោទ:
នួន ជា
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Anta GUISSÉ
លោក Arthur VERCKEN

## I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១- សាលក្រមសំណុំរឿង០០២/០១ ត្រូវបានចេញនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤[1]។ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៤ មេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានដាក់សំណើរួមមួយ ដោយសុំបន្ថែមចំនួនទំព័រ និងពេលវេលាលើសពីការកំណត់ សម្រាប់ការជូនដំណឹងបណ្តឹងសាទុក្ខរបស់ពួកគេ និងសារណាបណ្តឹងសាទុក្ខ[2]។ ក្រុមមេធាវីការពារក្តីបានស្នើសុំបន្ថែមចំនួនទំព័ររហូតដល់១៥០ទំព័រម្នាក់ៗ សម្រាប់សារណាបណ្តឹងសាទុក្ខរបស់ពួកគេ និងរហូតដល់១១៧ថ្ងៃ សម្រាប់ការបញ្ចប់សារណារបស់ពួកគេជាភាសាបារាំង ឬអង់គ្លេស បូករួមជាមួយពេលវេលាចំបាច់សម្រាប់ការបកប្រែ[3]។

២- ក្នុងសេចក្តីសម្រេចមួយចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូល (“អជតក”) បានទទួលស្គាល់អំពីភាពចាំបាច់នៃការបន្ថែមចំនួនទំព័រ និងពេលវេលាសម្រាប់បណ្តឹងសាទុក្ខ ប៉ុន្តែបានពន្យារពេលរហូតដល់ទទួលបានការជូនដំណឹងបណ្តឹងសាទុក្ខរបស់ភាគីជាមុនសិន[4]។

៣- នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ភាគីបានដាក់ការជូនដំណឹងបណ្តឹងសាទុក្ខរបស់ខ្លួន។ សហព្រះរាជអាជ្ញាបានជូនដំណឹងអង្គជំនុំជម្រះ និងភាគីថា សហព្រះរាជអាជ្ញាមានបំណងប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលច្រានចោលទម្រង់នៃការទទួលខុសត្រូវ នៃសហឧក្រិដ្ឋកម្មរួម[5]។ មេធាវីការពារក្តី នួន ជា បានជូនដំណឹងពីចេតនារបស់ខ្លួន ក្នុងការតវ៉ាទៅនឹង

---

[1] **E313** សាលក្រមសំណុំរឿង០០២/០១, ៧ សីហា ២០១៤។

[2] **F3** សំណើបន្ទាន់របស់មេធាវីការពារក្តី ខៀវ សំផន និងមេធាវីការពារក្តី នួន ជា សុំពន្យាពេលកំណត់ និងបន្ថែមចំនួនទំព័រនៃបណ្តឹងសាទុក្ខ, ១៣ សីហា ២០១៤។

[3] **F3** សំណើបន្ទាន់របស់មេធាវីការពារក្តី ខៀវ សំផន និងមេធាវីការពារក្តី នួន ជា សុំពន្យាពេលកំណត់ និងបន្ថែមចំនួនទំព័រនៃបណ្តឹងសាទុក្ខ, ១៣ សីហា ២០១៤, កថាខណ្ឌ៣០, ៣១។

[4] **F3/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ, ២៩ សីហា ២០១៤, កថាខណ្ឌ១០។

[5] **E313/3/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ស្តីពីបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនៅក្នុងសំណុំរឿង០០២/០១, ២៩ កញ្ញា ២០១៤។

ទទ្បីករណ៍ចំនួន២២៣ នៃបណ្តឹងសាទុក្ខ[6] ហើយមេធាវីការពារក្តី ខៀវ សំផន ក៏បានជូនដំណឹងពីចេតនារបស់ខ្លួន ក្នុងការតវ៉ាទៅនឹងទទ្បីករណ៍ចំនួនប្រហែល១៥០ នៃបណ្តឹងសាទុក្ខផងដែរ[7]។

៤- នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ មេធាវីការពារក្តី នួន ជា បានដាក់ "សំណើលើកទីពីរ សុំពន្យារពេល និងបន្ថែមចំនួនទំព័រ សម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម នៅក្នុងសំណុំរឿង០០២/០១"[8]។ មេធាវីការពារក្តី នួន ជា បានស្នើមិនឲ្យកំហិតចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខទេ ឬបើតាមជម្រើសផ្សេង ការកំហិតត្រូវមានចំនួន៥០០ទំព័រ[9]។ ពួកគេក៏ស្នើសុំពន្យារពេលពី៣០ថ្ងៃ (ដល់៩០ថ្ងៃជាសរុប ដោយគិតចាប់ពីថ្ងៃដាក់ការជូនដំណឹងបណ្តឹងសាទុក្ខរបស់ខ្លួន) រហូតដល់ការបញ្ជូនសារណាបណ្តឹងសាទុក្ខទៅបកប្រែ និងបន្ទាប់មក ត្រូវតែទទួលបានការអនុញ្ញាតឲ្យដាក់នៅពេលណាដែលការបកប្រែត្រូវបានបញ្ចប់[10]។ តាមរបៀបផ្សេងពីនេះ ពួកគេស្នើសុំពន្យារពេល៣០ថ្ងៃ ដើម្បីដាក់សារណាសុំការអនុញ្ញាតដាក់តែមួយភាសា ដោយសារណាបកប្រែជាភាសាខ្មែរនឹងត្រូវដាក់តាមក្រោយ នៅពេលបកប្រែចប់ និងលក្ខខណ្ឌមួយថា សារណាឆ្លើយតបត្រូវគិតចាប់ពីថ្ងៃដាក់សារណាបណ្តឹងសាទុក្ខតែមួយភាសា[11]។ មេធាវីការពារក្តី នួន ជា ប៉ាន់ប្រមាណថា បើសិនជាខ្លួនត្រូវបានអនុញ្ញាតរហូតដល់ ៥០០ទំព័រ ការបកប្រែទៅជាភាសាខ្មែរនឹងត្រូវការពេលវេលារហូតដល់ប្រាំខែ តែបើ១៥០ទំព័រ នឹងត្រូវការពេល៤៧ថ្ងៃ[12]។

---

[6] **E313/1/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ស្តីពីបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនៅក្នុងសំណុំរឿង០០២/០១, ២៩ កញ្ញា ២០១៤។

[7] **E313/2/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង០០២/០១, ២៩ កញ្ញា ២០១៤។

[8] **F6** "សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១", ២ តុលា ២០១៤។

[9] **F6** សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១", ២ តុលា ២០១៤, កថាខណ្ឌ៣-១២។

[10] **F6** សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១", ២ តុលា ២០១៤, កថាខណ្ឌ១៥។

[11] **F6** សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១", ២ តុលា ២០១៤, កថាខណ្ឌ១៦។

[12] **F6** សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១", ២ តុលា ២០១៤, កថាខណ្ឌ១៤។ ពីដើមដំបូង មេធាវីការពារក្តីប៉ាន់ប្រមាណថា ចំនួនទំព័រដូចគ្នានេះ នឹងត្រូវការពេល៤២ថ្ងៃនៃថ្ងៃធ្វើការ។ **F3** សំណើបន្ទាន់របស់មេធាវីការពារក្តី ខៀវ សំផន និងមេធាវីការពារក្តី នួន ជា សុំពន្យាពេលកំណត់ និងបន្ថែមចំនួនទំព័រនៃបណ្តឹងសាទុក្ខ, ១៣ សីហា ២០១៤, កថាខណ្ឌ៣០ និងកំណត់សម្គាល់ជើងទំព័រលេខ៣៩។

៥- នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៤ មេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើទីពីររបស់ខ្លួន ដោយសុំបន្ថែមចំនួនទំព័រ និងពេលវេលាសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០១[13]។ ក្នុងសំណើនេះ ពួកគេស្នើបន្ថែមចំនួនទំព័រដល់៣០០ជាភាសាបារាំង[14] និង ១១៤ថ្ងៃបន្ថែម (សរុប មានចំនួន១៧៤ថ្ងៃ គិតចាប់ពីថ្ងៃដាក់ការជូនដំណឹងបណ្តឹងសាទុក្ខរបស់ខ្លួន) ដើម្បីដាក់ទាំងពីរភាសា[15]។ មេធាវីការពារក្តី ខៀវ សំផន ប៉ានប្រមាណថា បើសិនជាខ្លួនត្រូវបានអនុញ្ញាតរហូតដល់៣០០ទំព័រ ការបកប្រែពីបារាំងទៅជាភាសាខ្មែរនឹងត្រូវការពេលវេលារហូតដល់៦០-៨៤ថ្ងៃនៃថ្ងៃធ្វើការ[16]។ មេធាវីការពារក្តី ខៀវ សំផន តវ៉ាថា គេមិនគួរមានលក្ខខណ្ឌតម្រូវណាមួយសម្រាប់ភាគីក្នុងការដាក់តែមួយភាសាជាមុន ហើយបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយនោះឡើយ[17] ប៉ុន្តែថា បើសិនជាមានលក្ខខណ្ឌតម្រូវដូច្នេះមែន ហើយពេលវេលាសម្រាប់ចម្លើយតបត្រូវគិតចាប់ពីថ្ងៃនោះមែន នោះពេលវេលាសម្រាប់ចម្លើយតបរបស់មេធាវីការពារក្តី ខៀវ សំផន មិនត្រូវរាប់ទេ រហូតដល់ពេលដែលពួកគេទទួលបានការបកប្រែជាភាសាបារាំងនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[18]។

៦- ហេតុដូច្នេះ សហព្រះរាជអាជ្ញាធ្វើការឆ្លើយតបទៅនឹងសំណើររបស់ក្រុមមេធាវីការពារក្តីទាំងពីរ ដូចតទៅ។ សហព្រះរាជអាជ្ញាក៏ធ្វើការសន្និដ្ឋានផងដែរថា គ្រប់ភាគីទាំងអស់ រួមទាំងគ្រប់ការិយាល័យរបស់ អ.វ.ត.ក និងអង្គជំនុំជម្រះដែលការងាររបស់ពួកគាត់នឹងប៉ះពាល់ ដោយសារតែកិច្ចដំណើរការនីតិវិធីប្តឹងសាទុក្ខនៃសំណុំរឿង០០២/០១ អាចទទួលបានប្រយោជន៍សម្រាប់គោលបំណងនៃការធ្វើការផែនការ តាមរយៈការបានដឹងជាមុនឆាប់រហ័សតាមដែលអាចធ្វើបាន នូវការកំណត់ពេលវេលាពេញលេញសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាចម្លើយតប។ អាស្រ័យហេតុនេះ ដើម្បីជៀសវាងការពន្យារពេលមិនចាំបាច់ តាមរយៈការដាក់ឯកសារដាច់ដោយឡែកពីគ្នានោះ សហព្រះរាជ

---

[13] **F7** ការស្នើសុំជាបន្ទាន់របស់ ខៀវ សំផន សុំពន្យារពេលកំណត់ និងបន្ថែមចំនួនទំព័រ នៅក្នុងសារណាបណ្តឹងសាទុក្ខ, ៦ តុលា ២០១៤។

[14] **F7** ការស្នើសុំជាបន្ទាន់របស់ ខៀវ សំផន សុំពន្យារពេលកំណត់ និងបន្ថែមចំនួនទំព័រ នៅក្នុងសារណាបណ្តឹងសាទុក្ខ, ៦ តុលា ២០១៤ កថាខណ្ឌ១៦។

[15] ការស្នើសុំជាបន្ទាន់របស់ ខៀវ សំផន សុំពន្យារពេលកំណត់ និងបន្ថែមចំនួនទំព័រ នៅក្នុងសារណាបណ្តឹងសាទុក្ខ, ៦ តុលា ២០១៤ កថាខណ្ឌ២០។

[16] **F7** ការស្នើសុំជាបន្ទាន់របស់ ខៀវ សំផន សុំពន្យារពេលកំណត់ និងបន្ថែមចំនួនទំព័រ នៅក្នុងសារណាបណ្តឹងសាទុក្ខ, ៦ តុលា ២០១៤ កំណត់សម្គាល់ជើងទំព័រ១៨។

[17] **F7** ការស្នើសុំជាបន្ទាន់របស់ ខៀវ សំផន សុំពន្យារពេលកំណត់ និងបន្ថែមចំនួនទំព័រ នៅក្នុងសារណាបណ្តឹងសាទុក្ខ, ៦ តុលា ២០១៤ កថាខណ្ឌ២២។

[18] **F7** ការស្នើសុំជាបន្ទាន់របស់ ខៀវ សំផន សុំពន្យារពេលកំណត់ និងបន្ថែមចំនួនទំព័រ នៅក្នុងសារណាបណ្តឹងសាទុក្ខ, ៦ តុលា ២០១៤ កថាខណ្ឌ២៣។

អាជ្ញាក៏ដាក់បញ្ចូលក្នុងចម្លើយតបនេះ នូវសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ សម្រាប់សារណាឆ្លើយតបរបស់ខ្លួនផងដែរ។

## II. ចម្លើយតប និងសំណើ

### ក. ការបន្ថែមចំនួនទំព័រ

៧- អនុលោមតាមសេចក្តីណែនាំអនុវត្ត មាត្រា ៥.២ ឯកសារដែលបានដាក់ទៅអង្គជំនុំជម្រះតុលាការកំពូល មិនត្រូវឲ្យលើសពី៣០ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ៦០ទំព័រ ជាភាសាខ្មែរឡើយ វៀរលែងតែមានការបង្គាប់ផ្សេងពីនេះដោយ អ.វ.ត.ក[19]។

*i. សំណើរបស់មេធាវីការពារក្តីសម្រាប់សារណាបណ្តឹងសាទុក្ខ*

៨- សហព្រះរាជអាជ្ញា ដូចអង្គជំនុំជម្រះតុលាការកំពូលដែរ ទទួលស្គាល់ថា ការបន្ថែមពេលវេលា និងចំនួនទំព័រសមស្រប គឺជាការចាំបាច់នៅក្រោមកាលៈទេសៈទាំងនេះ[20]។ អាស្រ័យដោយមូលហេតុនេះ សហព្រះរាជអាជ្ញាមិនជំទាស់នឹងសំណើដើម ដែលបានដាក់រួមគ្នាដោយក្រុមមេធាវីការពារក្តី ដែលបានស្នើសុំបន្ថែមចំនួនទំព័ររហូតដល់១៥០ទំព័រជាភាសាបារាំង ឬអង់គ្លេស សម្រាប់ភាសានិមួយៗនោះឡើយ[21]។ ប៉ុន្តែការស្នើសុំបន្ថែមចំនួនទំព័ររបស់មេធាវីការពារក្តី នៅពេលនេះ គឺច្រើនហួសហេតុ គ្មានមូលដ្ឋានសម្អាង និងមិនសម្រាប់ផលប្រយោជន៍យុត្តិធម៌ទេ។ ពេលនេះ មេធាវីការពារក្តី នួន ជា ស្នើសុំមិនឲ្យកំហិតចំនួនទំព័រទេ ឬតាមរបៀបផ្សេង ត្រូវឲ្យលើសបីដងនៃសំណើដើមរបស់ខ្លួន។ មេធាវីការពារក្តី ខៀវ សំផន នៅពេលនេះ ព្យាយាមចង់បានលើសពីរដងនៃសំណើដើមរបស់ខ្លួន។

៩- សហព្រះរាជអាជ្ញាទទួលស្គាល់ថា ការបន្ថែមលើសពី៣០ទំព័រ គួរតែត្រូវបានអនុញ្ញាត។ ឧទាហរណ៍ចំពោះចំណុចដែលបានលើកឡើងដោយមេធាវីការពារក្តីទាំងពីរក្រុម ដែលបានកម្រិតឱកាសសម្រាប់

---

[19] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៨, ស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, មាត្រា៥.២។

[20] **F3/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ, កថាខណ្ឌ១០។

[21] **F3/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន និង នួន ជា សុំពន្យារពេលកាលបរិច្ឆេទ និងបន្ថែមចំនួនទំព័រ ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០០១, ២១ សីហា ២០១៤, កថាខណ្ឌ៤។

បណ្តឹងសាទុក្ខបន្ទាន់បង្អុំក្នុងអំឡុងពេលសវនាការ បានបណ្តាលឲ្យមានជាទម្លាករណ៍នៃបណ្តឹងសាទុក្ខមួយចំនួនធំ ក្រោយពីមានសាលក្រម[22]។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់ផងដែរថា យុត្តាធិការនៃអង្គជំនុំជម្រះតុលាការកំពូលស្តីពីបណ្តឹងសាទុក្ខលើសាលក្រម គឺត្រូវបានកំណត់[23]។ សហព្រះរាជអាជ្ញាក៏ធ្វើសេចក្តីសន្និដ្ឋានផងដែរថា មូលហេតុជាច្រើនដែលបានលើកឡើងគាំទ្រដល់ការកម្រិតទំព័រដែលមានចំនួនច្រើនជាងមុន ជាពិសេសដែលបានលើកឡើងដោយមេធាវីការពារក្តី នួន ជា គឺមិនត្រឹមតែគ្មានន័យប៉ុណ្ណោះទេ ថែមទាំងប្រាប់ឲ្យដឹងពីប្រភេទនានានៃអំណះអំណាងដែលអាចរំពឹងថា ត្រូវដាក់ចំនួនទំព័រដែលលើសពីការចាំបាច់បំផុត ដែលបានអនុញ្ញាតឲ្យមេធាវីការពារក្តីធ្វើសារណាបណ្តឹងសាទុក្ខរបស់ខ្លួនទៀតផង ។

១០- អំណះអំណាងដែលបានលើកឡើងដោយមេធាវីការពារក្តី នួន ជា ទាក់ទងនឹងចំនួនទំព័រកំណត់ដ៏ច្រើននេះ រួមមានការអះអាងដែលថា៖ ១) នៅ អ.វ.ត.ក មិនមានការអនុវត្តនូវចំនួនទំព័រកំណត់ក្នុងការដាក់ឯកសារទេ[24], ២) ការឲ្យមានចំនួនទំព័រច្រើនគួរត្រូវបានបែងចែកឲ្យ ដើម្បីកែប្រែកំហុសនីតិវិធីដែលបានចោទប្រកាន់នៅដំណាក់កាលស៊ើបសួរ និងជំនុំជម្រះក្តីដែលនៅមិនទាន់បានបង្ហាញឲ្យឃើញនៅឡើយ[25], ៣) ពួកខ្លួនមានបំណងធ្វើអំណះអំណាងទាក់ទងនឹងកំហុសនានា ដែលបានចោទប្រកាន់លើអង្គហេតុ និងអង្គច្បាប់ ដែលបានទទួលយក គឺនៅក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះ ទាក់ទងនឹងបណ្តឹងសាទុក្ខនេះ[26], និង ៤) "សារណាបណ្តឹងសាទុក្ខវែងជាងនេះ"[27] គួរត្រូវបានអនុញ្ញាត ពីព្រោះពួកគាត់មានបំណងធ្វើសំណើ ដើម្បីឲ្យអង្គជំនុំជម្រះតុលាការកំពូលពិនិត្យ *ឡើងវិញ* លើអង្គហេតុដែលបានរកឃើញដោយអង្គជំនុំជម្រះសាលាដំបូង ដែលផ្ទុយនឹងសេចក្តីសម្រេចពីមុនរបស់អង្គជំនុំជម្រះ

[22] **F7** ការស្នើសុំជាបន្ទាន់របស់ ខៀវ សំផន សុំពន្យារពេលកំណត់ និងបន្ថែមចំនួនទំព័រ នៅក្នុងសារណាបណ្តឹងសាទុក្ខ, ៦ តុលា ២០១៤ កថាខណ្ឌ១៥។ **F6** សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១, ២ តុលា ២០១៤, កថាខណ្ឌទី៩។

[23] វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

[24] **F6** សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១, ២ តុលា ២០១៤, កថាខណ្ឌទី៣។

[25] **F6** សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១, ២ តុលា ២០១៤, កថាខណ្ឌទី៥។

[26] **F6** សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១, ២ តុលា ២០១៤, កថាខណ្ឌទី១១។

[27] **F6** សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១, ២ តុលា ២០១៤, កថាខណ្ឌទី១២។

តុលាការកំពូលស្តីពីបញ្ហានេះ[28]។ មិនមានអំណះអំណាងណាមួយក្នុងចំណោមអំណះអំណាងទាំងនេះ លេចចេញមកពីអង្គហេតុថ្មីដែលមិនបានបង្ហាញក្នុងរយៈពេល៦សប្តាហ៍មុននេះទេ នៅពេលដែលមេធាវីការពារក្តី នួន ជា បានស្នើសុំ១៥០ទំព័រនោះ ហើយមិនមានអំណះអំណាងណាមួយក្នុងចំណោមអំណះអំណាងទាំងនេះ មានសុពលភាពនៅក្នុងព្រឹត្តិការណ៍ណាមួយនោះទេ។ ចំនួនទទ្បីករណ៍តិចតួចនៃបណ្តឹងសាទុក្ខដែលដាក់នៅក្នុងការជូនដំណឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី បានផ្តល់ទម្ងន់តិចតួច ដើម្បីកំណត់ពីប្រវែងសមហេតុសមផលមួយ សម្រាប់សារណាបណ្តឹងសាទុក្ខតែប៉ុណ្ណោះ។ ទីមួយ បរិមាណនៃទទ្បីករណ៍បណ្តឹងសាទុក្ខដែលដាក់នៅក្នុងការជូនដំណឹងពីបណ្តឹងសាទុក្ខ គឺជាផលិតផលទាំងមូលរបស់ភាគីដាក់ឯកសារ ដោយពុំមានការពិនិត្យលើការកម្រិតណាមួយ ទាក់ទងទៅនឹងអង្គសេចក្តីឡើយ។ ទីពីរ ពុំមានលក្ខខណ្ឌតម្រូវណាមួយ ដែលភាគីមួយប្រាកដជាដាក់អំណះអំណាងលើគ្រប់ទទ្បីករណ៍ទាំងអស់ ដែលបានដាក់នៅក្នុងការជូនដំណឹងបណ្តឹងសាទុក្ខរបស់ខ្លួននោះឡើយ។ យ៉ាងណាក៏ដោយ គ្មានការហាមឃាត់មិនឲ្យលើកការតវ៉ាមួយដែលមិនមាននៅក្នុងការជូនដំណឹងស្តីពីបណ្តឹងសាទុក្ខឡើយ[29]។ ដូច្នេះ ភាគីនានាអាចនឹងត្រូវបានលើកទឹកចិត្តឲ្យដាក់បញ្ចូលទាំងស្រុងនៅក្នុងការជូនដំណឹងស្តីពីបណ្តឹងសាទុក្ខរបស់ខ្លួន ដើម្បីជ្រើសរើស និងពង្រឹងនូវអំណះអំណាងរឹងមាំបំផុតរបស់ខ្លួន ខណៈដែលពួកគេបានដំណើរការព្រាងឯកសាររបស់ខ្លួន។ ទីបី នៅពេលដែលភាគីនានាបានដាក់ការជូនដំណឹងបណ្តឹងសាទុក្ខរបស់ខ្លួន នោះពួកគេដូចជាបានការជូនដំណឹងពីសំណាក់អង្គជំនុំជម្រះនេះថា ការស្នើសុំបន្ថែមចំនួនទំព័រ និងពេលវេលាជាបន្តបន្ទាប់ មុខជានឹងត្រូវបានសម្រេច យ៉ាងហោចណាស់ក៏មួយផ្នែកដែរ ដោយឈរលើមូលដ្ឋាននៃ "ការកំណត់ដែលនឹងត្រូវផ្តល់ជូន នៅក្នុងសេចក្តីជូនដំណឹងបណ្តឹងសាទុក្ខ"[30]។ ការណ៍នេះ ទំនងជាបានផ្តល់នូវការលើកទឹកចិត្តមួយបន្ថែមទៀតដល់មេធាវីការពារក្តីឲ្យបំប៉ោងទទ្បីករណ៍បណ្តឹងសាទុក្ខ សម្រាប់ជាគោលបំណងនៃការធានាដល់ការបន្ថែមពេលវេលា និងចំនួនទំព័រឲ្យបានច្រើន។

១១- សូម្បីតែការអានដោយត្រួសៗនៃទទ្បីករណ៍បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ក៏បង្ហាញថាភាគច្រើននៃទទ្បីករណ៍ទាំងនេះ គឺរៀបរាប់ការរកឃើញអង្គហេតុ ឬសេចក្តីសម្រេចដែលគេមិនយល់ស្របដោយសារមិនបានកំណត់អត្តសញ្ញាណថា តើទទ្បីករណ៍ទាំងនេះអាចនឹងធ្វើឲ្យសាលក្រមនោះ អស់

[28] **F6** សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១, ២ តុលា ២០១៤, កថាខណ្ឌទី១២។

[29] វិធាន ១១០(១) នៃវិធានផ្ទៃក្នុង។

[30] **F3/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ, ២៩ សីហា ២០១៤, កថាខណ្ឌទី១០។

សុពលភាពយ៉ាងដូចម្ដេចនោះទេ។ មេធាវីការពារក្ដីដែលប្រកបទៅដោយបទពិសោធន៍បែបដូចជា មេធាវីការពារក្ដី នួន ជា និង ខៀវ សំផន ពិតជាបានដឹងថា បណ្ដឹងសាទុក្ខខ្លាំងមួយ មុខជានឹងមាន ការផ្ដោតទៅលើបញ្ហាកំណត់មួយចំនួនដែលមានអានុភាពធ្ងន់ទៅលើសាលក្រម ដែលនៅក្នុងនោះមាន ការលើកអំណះអំណាងគួរឱ្យទុកចិត្តបាន។ ការខកខានរបស់មេធាវីការពារក្ដី ក្នុងការធ្វើដូច្នេះ គឺមិន គ្រាន់តែឆ្លុះបញ្ចាំងពីការមិនមានទំនុកចិត្ត នៅក្នុងភាពស្របច្បាប់នៃអំណះអំណាងណាមួយរបស់ពួក គេប៉ុណ្ណោះនោះទេ។ វិធីសាស្ត្របាញ់កាំភ្លើងរបស់ពួកគេ ក៏មានន័យផងដែរថា គោលបំណងនៃការជូន ដំណឹង ដើម្បីប្រាប់ដល់អង្គជំនុំជម្រះតុលាការកំពូល និងភាគីប្រឆាំងនានាថាបញ្ហានេះ គឺបានបង្អាក់ទឹក ចិត្តយ៉ាងខ្លាំង។

១២- ចំនួនទំព័រកំណត់ច្រើនមិនសមហេតុសមផល នឹងគ្រាន់តែពន្យារដំណើរការជឿនលឿននៃកិច្ចដំណើរ ការនីតិវិធីប៉ុណ្ណោះ ដោយមិនបានធ្វើវិភាគទានដល់គុណភាពឡើយ។ ដោយហេតុថា ពីមុនមក សហ ព្រះរាជអាជ្ញាធ្លាប់បានកត់សម្គាល់ថា វិធាន២១នៃវិធានផ្ទៃក្នុង បានផ្ដល់អាណត្តិ មិនត្រឹមតែថា “ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌” និង “រក្សាបាននូវតុល្យភាពរវាង សិទ្ធិរបស់ភាគីទាំងឡាយ”ប៉ុណ្ណោះទេ ថែមទាំងថា “នីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវ បញ្ចប់ក្នុងរយៈពេលមួយសមស្រប”[31]។ មេធាវីការពារក្ដី នួន ជា លើកឡើងថា ៥០០ទំព័រ នឹងត្រូវប្រើ រយៈពេលចំនួន៥ខែ ដើម្បីបកប្រែទៅភាសាខ្មែរដែលជាភាសាតម្រូវការ[32]។ ហេតុដូច្នេះ តាមការ គណនាផ្ទាល់របស់មេធាវីការពារក្ដី បើសិនក្រុមនីមួយៗត្រូវបានអនុញ្ញាត ឱ្យចំនួន៥០០ទំព័រ ដូចដែល បានស្នើសុំដោយមេធាវីការពារក្ដី នួន ជា នោះសារណា របស់មេធាវីការពារក្ដីនឹងមានចំនួនសរុប ១០០០ទំព័រ ហើយខាងអយ្យការត្រូវបាន អនុញ្ញាតឱ្យមានចំនួនទំព័រស្មើគ្នា ដើម្បីធ្វើការឆ្លើយតប នោះ ការបកប្រែភាសាលើសារណារបស់ ភាគីទាំងឡាយដែលមានចំនួន២០០០ទំព័រ មុខជានឹងត្រូវប្រើពេល ចំនួន២០ខែ។ ការផ្លាស់ប្ដូរភ្លាមៗនៅក្នុងសំណើរបស់មេធាវីការពារក្ដី នួន ជា ពីចំនួន១៥០ទំព័រ ទៅ ចំនួន៥០០ទំព័រ មិនសមហេតុសមផលទាល់តែសោះ ទំនងជាកលយុទ្ធប្រកបទៅដោយកលល្បិច។

១៣- ដូចដែលមេធាវីការពារក្ដីទាំងពីរក្រុមបានទទួលស្គាល់ដូច្នោះដែរ “គុណភាព និងប្រសិទ្ធភាពនៃ សារណាបណ្ដឹងសាទុក្ខ មិនមែនអាស្រ័យលើប្រវែងនោះទេ គឺអាស្រ័យលើភាពច្បាស់លាស់ និងភាព

[31] វិធាន ២១(៤) នៃវិធានផ្ទៃក្នុង (សង្កត់ន័យបន្ថែមដោយ គូសបន្ទាត់ពីក្រោម)។

[32] **F6** សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១, ២ តុលា ២០១៤, កថាខណ្ឌទី១៤។

ជឿជាក់ និងត្រឹមត្រូវនៃទឡ្ហីករណ៍”[33]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក៏បានថ្លែងផងដែរថា ដោយសារតែគោលការណ៍ “សារណាវែងហួសហេតុ មិនបានសម្រួលជាចាំបាច់ដល់ប្រសិទ្ធភាពរដ្ឋបាលតុលាការទេ”[34]។ ដូច្នេះ សារណាវែងហួសហេតុដែលបានស្នើសុំដោយមេធាវីការពារក្តី មិនគួរត្រូវបានអនុញ្ញាតឲ្យទេ។ ទោះបីជាសហព្រះរាជអាជ្ញាស្នើសុំថា មេធាវីការពារក្តីមួយក្រុមៗ មានទំព័រកំណត់មួយសមហេតុសមផលចំនួន១៥០ទំព័រ ជាភាសាបារាំង ឬអង់គ្លេសក៏ដោយ ក៏សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការបន្ថែមចំនួនទំព័ររហូតដល់ទៅ២០០ទំព័រ ជាភាសាបារាំង ឬអង់គ្លេស សម្រាប់មេធាវីការពារក្តីមួយក្រុមៗដែរ។

*ii. សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំដាក់សារណាតប*

១៤- សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល មេត្តាអនុញ្ញាតឲ្យមានការបន្ថែមចំនួនទំព័រកំណត់សម្រាប់ចម្លើយតបរបស់ខ្លួននៅពេលនេះ តបទៅនឹងសារណាបណ្តឹងសាទុក្ខចំនួន២ របស់មេធាវីការពារក្តី ដើម្បីឲ្យគ្រប់ភាគី ការិយាល័យនានារបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង[35] និងសាធារណជន អាចធ្វើផែនការទាំងមូលលើកាលវិភាគសម្រាប់ធ្វើសារណា។

១៥- ចំនួនទំព័រកំណត់ និងពេលវេលា ដែលសហព្រះរាជអាជ្ញាចាំបាច់ត្រូវឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខទាំងឡាយរបស់មេធាវីការពារក្តី មានការជាប់ទាក់ទងគ្នាយ៉ាងខ្លាំងទៅនឹងការបន្ថែម ដែលបានអនុញ្ញាតឲ្យដល់មេធាវីការពារក្តី ដើម្បីធ្វើសារណាសាទុក្ខរបស់ខ្លួន។ ដូច្នេះ សហព្រះរាជអាជ្ញាស្នើថា សហព្រះរាជអាជ្ញាគួរត្រូវបានអនុញ្ញាតឲ្យមានចំនួនទំព័រដូចគ្នាសម្រាប់ចម្លើយតបរបស់ខ្លួន ទៅនឹងចំនួនទំព័រសរុបរួមនៃសារណាសាទុក្ខរបស់មេធាវីការពារក្តីទាំងពីរក្រុម (*គឺថា* បើសិនជាមេធាវីការ

---

[33] **F3** សំណើបន្ទាន់របស់មេធាវីការពារក្តី ខៀវ សំផន និងមេធាវីការពារក្តី នួន ជា សុំពន្យាពេលកំណត់ និងបន្ថែមចំនួនទំព័រនៃបណ្តឹងសាទុក្ខ, ១៣ សីហា ២០១៤, កថាខណ្ឌទី២៩ (ដោយបានដកស្រង់ករណី *រដ្ឋអាជ្ញា ទល់នឹង Stanisic and Zupljanin,* សំណុំរឿងលេខ IT-08-91-A, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំបន្ថែមពេលវេលាដើម្បីដាក់ការជូនដំណឹងស្តីពីបណ្តឹងសាទុក្ខ, ១៦ មេសា ២០១៣, ទំព័រទី២)។

[34] *រដ្ឋអាជ្ញា ទល់នឹង Stanišić and Simatović,* សំណុំរឿងលេខ IT-03-69-A, សេចក្តីសម្រេចលើសំណើបន្ទាន់របស់ Stanišić ស្នើសុំបន្ថែមចំនួនទំព័រកំណត់, ៣១ តុលា ២០១៣, ទំព័រទី២)។

[35] អង្គជំនុំជម្រះសាលាដំបូងនឹងចាប់ផ្តើមបើកសវនាការលើសំណុំរឿង០០២/០២ ក្នុងពេលឆាប់ៗនេះ ដោយមានការកំណត់កាលវិភាគបំពេញក្នុងគោលបំណងដើម្បីសម្របសម្រួលដល់កិច្ចការរបស់ភាគីនានាស្តីពីសារណាបណ្តឹងសាទុក្ខលើសាលក្រមក្នុងសំណុំរឿង០០២/០១។ **E316** ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០២, ១៩ កញ្ញា ២០១៤, ទំព័រទី៣។

ពារក្តីនីមួយៗត្រូវបានអនុញ្ញាតឲ្យមានចំនួន២០០ទំព័រ ជាភាសាអង់គ្លេស ឬបារាំង នោះសហព្រះរាជអាជ្ញាស្នើសុំចំនួន៤០០ទំព័រ ជាភាសាអង់គ្លេស ឬបារាំង សម្រាប់ចម្លើយតបរបស់ខ្លួន)។

១៦- គឺជាការត្រឹមត្រូវ និងប្រកបដោយសនិទានភាពដែលថា សហព្រះរាជអាជ្ញាត្រូវបានផ្តល់ជូននូវបរិមាណទំព័រដូចៗគ្នា សម្រាប់ឆ្លើយតបទៅនឹងអំណះអំណាងទាំងឡាយដែលបានធ្វើឡើង ដូចដែលសហព្រះរាជអាជ្ញាត្រូវធ្វើ។ នេះជាការសមហេតុសមផល ពីព្រោះមេធាវីការពារក្តីនីមួយៗក្នុងចំណោមមេធាវីការពារក្តីទាំងពីរក្រុម អាចនឹងបញ្ចប់ដោយការលះបង់នូវចំនួនទំព័ររបស់ខ្លួនទាំងស្រុងដែលបានបែងចែកឲ្យ សម្រាប់ធ្វើបណ្តឹងសាទុក្ខដែលមានមូលដ្ឋានខុសគ្នា ដោយសារការរៀបចំគម្រោង ឬក៏ដោយសារពេលវេលាជួនគ្នា ហើយអាស្រ័យហេតុនេះ សិទ្ធិស្មើគ្នាក្នុងការការពារក្តីអាចកំណត់អាណត្តិថា សហព្រះរាជអាជ្ញាមានចំនួនទំព័រដូចគ្នាសម្រាប់ឆ្លើយតប[36]។ ជាការវាស់ដោយប្រៀបចំនួននៃហេតុផល ដែលមាននៅក្នុងសេចក្តីជូនដំណឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីទាំងពីរ មានភស្តុតាងច្បាស់ថា មេធាវីការពារក្តី នួន ជា យ៉ាងតិចបំផុតក៏មានហេតុផលចំនួន៧៣ដែរ សម្រាប់ប្តឹងសាទុក្ខ ដែលមេធាវីការពារក្តី ខៀវ សំផន មិនមាននោះ។ លើសពីនេះ សូម្បីតែនៅក្នុងស្ថានភាពដែលអាចមានភាពជាន់គ្នា រវាងអំណះអំណាងរបស់មេធាវីការពារក្តីទាំងនោះទាក់ទងនឹងកម្មវត្ថុក៏ដោយ ក៏អំណះអំណាងទាំងនោះអាចត្រូវបានធ្វើ ដោយផ្អែកលើមូលដ្ឋានដាច់ដោយឡែកពីគ្នា ឬក៏ផ្អែកទៅលើប្រភពសម្អាងផ្លូវច្បាប់ខុសៗគ្នា ដែលតាមរយៈនេះ ត្រូវការចាំបាច់ឲ្យមានចម្លើយតបចំនួនពីរដាច់ដោយឡែកពីគ្នា លើបញ្ហាដូចគ្នារបស់សហព្រះរាជអាជ្ញា។

១៧- អាស្រ័យទៅលើខ្លឹមសារនៃសារណារបស់មេធាវីការពារក្តី សហព្រះរាជអាជ្ញា ជាចុងក្រោយ មិនអាចត្រូវការជាចាំបាច់នូវចំនួនទំព័រពេញលេញ ស្មើនឹងចំនួនទំព័រសរុបដែលបានផ្តល់ទៅជូនមេធាវីការពារក្តីទាំងនោះឡើយ។ អាចថា សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារទាំងពីរក្រុម នឹងមានកន្លែងជាន់គ្នាច្រើន ប៉ុន្តែអាចថាសារណាទាំងនោះមិនមានកន្លែងជាន់គ្នាដែរ។ បើសិនជា សហព្រះរាជអាជ្ញាអាចដោះស្រាយបានគ្រប់គ្រាន់ចំពោះបញ្ហាទាំងនេះ ដោយប្រើចំនួនទំព័រតិចជាងនេះ នោះយើងខ្ញុំនឹងដាក់សារណាឆ្លើយតបខ្លីជាងនេះ។ ក៏ប៉ុន្តែ ដោយសារតែខ្លឹមសារ និងរចនាបទនៃសារណាបណ្តឹងសាទុក្ខ

[36] សូមមេត្តាអាន *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Bahar Idriss Abu Garda*, សំណុំរឿងលេខ ICC-02/05-02/09, សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តី សុំបន្ថែមចំនួនទំព័រពីលើចំនួនកំណត់ ដើម្បីមេធាវីការពារក្តីធ្វើចម្លើយតបទៅនឹងពាក្យសុំរបស់រដ្ឋអាជ្ញាដែលសុំការអនុញ្ញាត្តិដើម្បីប្តឹងសាទុក្ខ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០/ទំព័រ៤ ("គោលការណ៍ស្តីពីសិទ្ធិស្មើគ្នារវាងភាគីនានា ដែលស្នើសុំអោយមេធាវីមានសិទ្ធិដាក់ចម្លើយតបទៅនឹងពាក្យសុំរបស់រដ្ឋអាជ្ញាដែលសុំប្តឹងសាទុក្ខនៅក្នុងលក្ខខណ្ឌដូចគ្នានឹងការណ៍ដែលរដ្ឋអាជ្ញាបានដាក់ពាក្យសុំនោះដែរ")។

របស់មេធាវីការពារក្តីដែលជាកត្តាកំណត់អំពីប្រវែង ដែលសហព្រះរាជអាជ្ញាត្រូវការចាំបាច់សម្រាប់ធ្វើការឆ្លើយតប ហើយទាំងអស់នេះសុទ្ធតែមិនទាន់ដឹងនៅឡើយ សហព្រះរាជអាជ្ញាគួរទទួលបានផលប្រយោជន៍ពីការមន្ទិលសង្ស័យនេះ។

១៨- សហព្រះរាជអាជ្ញាក៏សន្និដ្ឋានផងដែរថា ការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខនីមួយៗរបស់មេធាវីការពារក្តីទាំងពីរដាច់ពីគ្នា គួរតែជាសិទ្ធិរបស់សហព្រះរាជអាជ្ញា ហើយបើសិនជាសហព្រះរាជអាជ្ញាធ្វើដូច្នេះ ក្នុងពេលនេះ សហព្រះរាជអាជ្ញាគួរតែបានទទួលចំនួនទំព័រស្មើនឹងចំនួនទំព័រនៃសារណាបណ្តឹងសាទុក្ខរួមរបស់មេធាវីការពារក្តី។ ក្នុងពេលបច្ចុប្បន្ននេះ នៅមុនពេលអនុញ្ញាតឲ្យបន្ថែមចំនួនទំព័រ ទាំងបណ្តឹងសាទុក្ខ និងទាំងសារណាឆ្លើយតប គឺត្រូវធ្វើក្នុងចំនួន៣០ទំព័រជាកំណត់ ជាភាសាអង់គ្លេស ឬជាភាសាបារាំង[37]។ ហេតុដូចនេះ សហព្រះរាជអាជ្ញាអាចធ្វើការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខចំនួន៣០ទំព័រជាពីរ ដោយសារណាឆ្លើយតបចំនួន៣០ទំព័រជាពីរដែរ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ពុំមានហេតុផលណាដែលថា ភាគីមិនគួរទទួលបានការបន្ថែមពីលើចំនួនកំណត់ នៅពេលដែលសហព្រះរាជអាជ្ញាត្រូវធ្វើចម្លើយតបរួមនោះ។

១៩- ដើម្បីឲ្យមានភាពទៀងទាត់ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ចំនួនទំព័រសរុបទាំងអស់ដែលបានបញ្ជាក់នៅក្នុងនេះ គឺរួមបញ្ចូលទាំងកំណត់សម្គាល់លេខយោងជើងទំព័រ និងម្យ៉ាងទៀត ដើម្បីអនុវត្តឲ្យស្របទៅតាមសេចក្តីណែនាំអនុវត្តដែលពាក់ព័ន្ធ[38]។

## ខ. អំពីការបន្ថែមពេលវេលា

២០- អនុលោមតាមតាមវិធាន១០៧(៤)នៃវិធានផ្ទៃក្នុង សារណាបណ្តឹងសាទុក្ខ គឺត្រូវដាក់ជូននៅក្នុងរយៈពេល៦០ថ្ងៃយ៉ាងយូរ គិតចាប់តាំងពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្តឹងសាទុក្ខ ប៉ុន្តែ អង្គជំនុំជម្រះ

[37]សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធ. លើកទី៨, ស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក,មាត្រា ៥.២។

[38] សហព្រះរាជអាជ្ញាកត់សម្គាល់អំពីករណីដែលក្រុមមេធាវីការពារក្តី នួន ជា មិនអនុវត្តតាមលក្ខខណ្ឌតម្រូវបន្ទាត់ចន្លោះឃ្លាតគ្នា ១.៥ពីមួយទៅមួយ នៅក្នុងភាគច្រើននៃការជូនដំណឹងអំពីការប្តឹងសាទុក្ខ។ សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធ. លើកទី៨, ស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក,មាត្រា ៣.៨។

មានអំណាចបន្ថែមរយៈពេលថែមពីលើកាលបរិច្ឆេទកំណត់នេះបាន[39]។ មិនមានរយៈពេលកំណត់សម្រាប់ការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខទេ។

### *i. សំណើរបស់មេធាវីការពារក្តីសុំធ្វើសារណាបណ្តឹងសាទុក្ខ*

២១- សហព្រះរាជអាជ្ញាមិនជំទាស់ទេ ចំពោះសំណើរបស់មេធាវីការពារក្តី នួន ជា ដែលសុំបន្ថែមរយៈពេល ៣០ថ្ងៃ ពីលើរយៈពេលកំណត់ (សរុបត្រូវជា៩០ថ្ងៃ គិតចាប់តាំងពីថ្ងៃជូនដំណឹងលើបណ្តឹងសាទុក្ខ) ដើម្បីដាក់សារណាសាទុក្ខតែមួយភាសាប៉ុណ្ណោះ។ ប៉ុន្តែ ដូចដែលបានពិភាក្សាបន្ថែមខាងក្រោមនេះ ទាក់ទងនឹងចម្លើយតបទៅនឹងសារណាសាទុក្ខ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងការសំណូមពររបស់មេធាវីការពារក្តី នួន ជា ដែលថា រយៈពេលឆ្លើយតបគួរត្រូវចាប់ផ្តើម ពីពេលដាក់ឯកសារតែមួយភាសា។ សហព្រះរាជអាជ្ញាជំទាស់ចំពោះសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដែលសុំរយៈពេល ១៧៤ថ្ងៃ ដោយគិតពីពេលដាក់ការជូនដំណឹងស្តីពីការប្តឹងសាទុក្ខដើម្បីដាក់ឯកសារជាពីរភាសា ដែលមានលក្ខណៈច្រើនហួសហេតុ និងមិនមែនសម្រាប់ផលប្រយោជន៍យុត្តិធម៌ ព្រោះមិនបាននាំមកនូវដំណោះស្រាយចំពោះដំណើរការនីតិវិធីឲ្យបានទាន់ពេលនោះទេ។ តាមកាលវិភាគដែលបានស្នើឡើងដោយមេធាវីការពារក្តី ខៀវ សំផន ដែលអនុញ្ញាតសម្រាប់រយៈពេលឆ្លើយតប ស្មើគ្នានឹងរយៈពេលដែលបានអនុញ្ញាតសម្រាប់មេធាវីការពារក្តីនីមួយៗ ក្នុងការធ្វើបណ្តឹងសាទុក្ខរបស់ខ្លួន មានន័យថា ការធ្វើសារណានឹងមិនទាន់រួចរាល់ទេ រហូតដល់ប្រហែលខែកញ្ញា ឆ្នាំ២០១៥ឯណោះ។ ការណ៍នេះមិនបង្កើតឲ្យមានការបញ្ចប់នីតិវិធីក្នុង "ពេលវេលាសមស្រប" ដូចដែលបានកំណត់ដោយវិធាន២១ នៃវិធានផ្ទៃក្នុងឡើយ។

### *ii. សំណើរបស់សហព្រះរាជអាជ្ញា ដោយមានលក្ខខណ្ឌ ក្នុងការធ្វើសារណាសាទុក្ខ*

២២- សហព្រះរាជអាជ្ញាស្នើថា បើសិនជាអង្គជំនុំជម្រះបន្ថែមរយៈពេលសម្រាប់ដាក់សារណាសាទុក្ខឲ្យភាគីនានានៅក្នុងសំណុំរឿង០០២/០១ នោះកាលបរិច្ឆេទដូចគ្នាគួរត្រូវអនុវត្តចំពោះសហព្រះរាជអាជ្ញាដែរ ដោយសារមូលហេតុភាពងាយស្រួល និងភាពដូចគ្នានៅក្នុងការកំណត់កាលបរិច្ឆេទសម្រាប់ការធ្វើ

[39] សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធ. លើកទី៨, ស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក,មាត្រា ៨.១។ វិធាន៣៩ នៃវិធានផ្ទៃក្នុង។

សារណា ឬសវនាការលើបណ្ដឹងសាទុក្ខជាបន្តបន្ទាប់។ ហេតុដូចនេះ ថាតើអង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីការពារក្ដី នូវរយៈពេល៣០ថ្ងៃ, ១៧៤ថ្ងៃ, ឬមួយក៏បន្ថែមពេលវេលាទៀត ពេលវេលាកំណត់ដូចគ្នាគួរតែអនុវត្តចំពោះការដាក់សារណាសាទុក្ខរបស់សហព្រះរាជអាជ្ញា។

### *iii. សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់សារណាឆ្លើយតប*

២៣- សហព្រះរាជអាជ្ញាសន្និដ្ឋានថា គួរចេញដីកាបង្គាប់ឲ្យមេធាវីការពារក្ដីដាក់ឯកសារតែមួយភាសា នៅថ្ងៃ ឬនៅមុនពេលផុតកំណត់ការបន្ថែមរយៈពេល៣០ថ្ងៃ បើសិនទទួលបាន ប៉ុន្តែរយៈពេលសម្រាប់ឆ្លើយតប មិនគួរចាប់ផ្ដើមទេ រហូតដល់ពេលទទួលបានការបកប្រែទៅជាភាសាទីពីរដែលជាលក្ខខណ្ឌតម្រូវ (សន្មតភាសាខ្មែរ)។ រយៈពេលការឆ្លើយតបនោះ មិនត្រូវចាប់ផ្ដើមទេ រហូតដល់ពេលមានការដាក់ឯកសារជាភាសាខ្មែរ ហើយយ៉ាងហោចណាស់ក៏មានភាសាអង់គ្លេស ឬភាសាបារាំង យោងតាមសេចក្ដីណែនាំអនុវត្ត[40] និងបទដ្ឋាននៃការអនុវត្តរបស់ អវតក។ គ្មានមូលហេតុទេដើម្បីងាកចេញពីបទដ្ឋាននៃការអនុវត្តនៅទីនេះ ហើយសហព្រះរាជអាជ្ញាអាចទទួលការខូចខាត បើសិនការណ៍នេះកើតឡើង ចំពោះរយៈពេលដែលបុគ្គលិករបស់ការិយាល័យសហព្រះរាជអាជ្ញាធ្វើការងារលើភាសាខ្មែរ រួមមាន សហព្រះរាជអាជ្ញាជាតិ អាចត្រូវបានកាត់បន្ថយ។ ការកាត់បន្ថយបែបនេះ មិនគ្រាន់តែប៉ះពាល់ដល់ផលប្រយោជន៍ប៉ុណ្ណោះទេ ថែមទាំងធ្វើឲ្យមានភាពមិនត្រឹមត្រូវចំពោះអង្គជំនុំជម្រះដែលស្ថិតនៅក្នុងតុលាការរបស់កម្ពុជា ហើយដែលក្នុងករណីនេះ ភាសាជាផ្លូវការ គឺភាសាខ្មែរ[41]។

២៤- សហព្រះរាជអាជ្ញាស្នើផងដែរថា ការអនុញ្ញាតឲ្យមានរយៈពេលបន្ថែមដូចគ្នា ចំពោះមេធាវីការពារក្ដីនីមួយៗ សម្រាប់ធ្វើសារណាសាទុក្ខ នោះគួរតែត្រូវអនុញ្ញាតឲ្យសហព្រះរាអាជ្ញាផងដែរ សម្រាប់ធ្វើសារណាឆ្លើយតប។ អាស្រ័យហេតុនេះ បើសិនអង្គជំនុំជម្រះអនុញ្ញាតបន្ថែមរយៈពេល៣០ថ្ងៃពីលើរយៈពេលកំណត់ (សរុបត្រូវ៩០ថ្ងៃចាប់ពីការជូនដំណឹងស្ដីពីការប្ដឹងសាទុក្ខ) ដល់មេធាវីការពារក្ដីនីមួយៗ ដើម្បីដាក់សារណាសាទុក្ខរបស់ខ្លួនតែមួយភាសា នោះសហព្រះរាជអាជ្ញាអាចទទួលបានផងដែររយៈពេល៩០ថ្ងៃ គិតចាប់ពីពេលបានទទួលសារណារបស់មេធាវីការពារក្ដីជាពីរភាសា ដើម្បីដាក់ចម្លើយតបរបស់ខ្លួនតែមួយភាសា។ ដោយស្ថិតនៅក្នុងស្ថានភាពប្រថុយប្រថាន ក្នុងការថ្លែងបញ្ជាក់

---

[40] សេចក្ដីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធ. លើកទី៨, ស្ដីពីការដាក់ឯកសារនៅចំពោះមុខ អវតក,មាត្រា ៧.១។

[41] កិច្ចព្រមព្រៀង អវតក,មាត្រា២៦(១)។

ពីភាពជាក់ស្តែង ហេតុដូចនេះ សហព្រះរាជអាជ្ញាស្នើតែរយៈពេលពាក់កណ្តាលនឹងរយៈពេលរួមដែលមេធាវីការពារក្តីបានចំណាយក្នុងការធ្វើសារណាសាទុក្ខ ដែលសហព្រះរាជអាជ្ញាត្រូវធ្វើការឆ្លើយតប។ ដោយសារតែការណ៍នេះធ្វើឱ្យសហព្រះរាជអាជ្ញាស្ថិតនៅក្នុងស្ថានភាពបាត់បង់ផលប្រយោជន៍ នេះជាការធ្វើសម្បទានដែលសហព្រះរាជអាជ្ញាមានបំណងចង់ធ្វើ ដើម្បីផ្តល់ផលប្រយោជន៍ដល់យុត្តិធម៌បានទាន់ពេលវេលា។

## III. ដំណោះស្រាយដែលបានស្នើសុំ

២៥- អាស្រ័យដោយមូលហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះ មេត្តា៖

(ក) ផ្តល់ឱ្យក្រុមមេធាវីការពារក្តីបន្ថែមចំនួនទំព័រ ដើម្បីធ្វើសារណាសាទុក្ខ ជាភាសាអង់គ្លេស ឬភាសាបារាំងមិនឱ្យលើសពី២០០ទំព័រ ដែលក្នុងនោះរួមទាំង សេចក្តីពន្យល់នៅលេខយោងជើងទំព័រផង។

(ខ) ផ្តល់ឱ្យសហព្រះរាជអាជ្ញាបន្ថែមចំនួនទំព័រ ដើម្បីធ្វើសារណាឆ្លើយតប មិនឱ្យតិចជាងចំនួនទំព័ររបស់ក្រុមមេធាវីការពារក្តី ចំពោះសារណាសាទុក្ខរួម របស់ក្រុមមេធាវីការពារក្តី។

(គ) ផ្តល់ឱ្យក្រុមមេធាវីការពារក្តីបន្ថែមរយៈពេល៣០ថ្ងៃ សម្រាប់ដាក់សារណាសាទុក្ខតែមួយភាសា ដោយឯកសារបកប្រែជាភាសាខ្មែរដាក់តាមក្រោយ ក្នុងរយៈពេលឆាប់តាមដែលអាចធ្វើទៅបាន។

(ឃ) កំណត់កាលបរិច្ឆេទសម្រាប់សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី ដាក់សារណាសាទុក្ខ នៅកាលបរិច្ឆេទតែដូចគ្នា។ និង

(ង) ផ្តល់ឲ្យសហព្រះរាជអាជ្ញាបន្ថែមពេលវេលាដូចគ្នា ដើម្បីដាក់សារណាឆ្លើយតបតែមួយភាសា ដូចគ្នានឹងក្រុមមេធាវីការពារក្តីដែរ ដើម្បីដាក់សារណាសាទុក្ខ ដោយឯកសារបកប្រែជាភាសាខ្មែរដាក់តាមក្រោយ ក្នុងរយៈពេលឆាប់តាមដែលអាចធ្វើទៅបាន។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Nicholas KOUJIAN<br>សហព្រះរាជអាជ្ញា | | |